# ម៉ូតសក់ក្នុងសិល្បៈខ្មែរ សម័យមុនអង្គរនិងសម័យអង្គរ

## មូលន័យសង្ខេប

*តាមរយៈស្នាដៃសិល្បៈខ្មែរ ជាពិសេសចម្លាក់ដែលបានបន្សល់ទុកដោយបុព្វបុរសខ្មែរ យើងអាចសិក្សាបាននូវម៉ូតសក់ទាំងឡាយនៅក្នុងសង្គមខ្មែរបុរាណ ជាពិសេសនៅសម័យអង្គរ ដែលមានអរិយធម៌ដ៏រុងរឿងបំផុតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះបានឈានដល់ការកំណត់ម៉ូតសក់តាមរចនាបថនៅសម័យមុនអង្គរនិងសម័យអង្គរ តាមរយៈការសិក្សាវិភាគធ្វើចំណាត់ថ្នាក់និងពិនិត្យផ្ទៀងផ្ទាត់លើចម្លាក់លោតឬចម្លាក់មូល(បដិមា)នៅតាមសារៈមន្ទីរទាំងក្នុងប្រទេសនិងក្រៅប្រទេសដែលមានការផ្សព្វផ្សាយនៅតាមបណ្ដាញសង្គម និងលើចម្លាក់លៀននៅតាមប្រាសាទចំនួនជាង៣០ប្រាសាទ (ចម្លាក់អប្សររូបធំពេញដំហរ និងចម្លាក់រូបតូចៗជាខ្សែរឿង) សរុបប្រមាណជាង ៤០០០រូប។ ជាលទ្ធផល យើងអាចកំណត់ម៉ូតសក់ទាំងស្ត្រីទាំងបុរសតាមរចនាបថគឺ នៅសម័យមុនអង្គរ(ពីរចនាបថភ្នំដាដល់រចនាបថកំពង់ព្រះ)មានចំនួន២៧ម៉ូត, ម៉ូតសក់ពីរចនាបថគូលែនដល់រចនាបាពួនមានចំនួន៤២ម៉ូត, ម៉ូតសក់ក្នុងរចនាបថអង្គវត្តមានចំនួន១០៩ម៉ូត និង ម៉ូតសក់ក្នុងរចនាបថបាយ័នមានចំនួន៣៤ម៉ូត។ ជាមួយនេះ ការសិក្សាក៏បានពិនិត្យលើគ្រឿងតុបតែងលម្អសក់អប្សរដែរ មានដូចជា បូ ស្នៀត ក្បាំងសក់ឬស្បៃ និង ក្បាំងមកុដ ជាដើម ដែលគ្រឿងតុបតែងទាំងនេះបានធ្វើឱ្យម៉ូតសក់កាន់តែមានសោភណភាពប្លែកៗបន្ថែមទៀត។*

*យើងឃើញថា ម៉ូតសក់ក្នុងសិល្បៈខ្មែរពីរចនាបថមួយទៅរចនាបថមួយមានលំនាំបន្តគ្នា ដោយមានការកែច្នៃឬដោយមិនកែច្នៃ តែក៏មានម៉ូតសក់ថ្មីដោយឡែកជាអត្តសញ្ញាណផ្ទាល់នៅក្នុងរចនាបថនីមួយៗដែរ។ ជាងនេះទៀត មានម៉ូតសក់ខ្លះនៅមានអត្ថិភាពនិងកំពុងពេញនិយមនៅឡើយ ទាំងនៅក្នុងសង្គមខ្មែរនិងនៅបរទេស តែក៏មានម៉ូតសក់ខ្លះមិនធ្លាប់បានឃើញមាននៅក្នុងសិល្បៈផ្សេងៗនៅលើសាកលលោកដែរ។*

*លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះជាផ្នែកដ៏ចម្បងមួយនៃការអភិរក្សអត្តសញ្ញាណម៉ូតសក់នៅក្នុងសង្គមខ្មែរនាសម័យបុរាណដ៏រុងរឿង។*